សន្លឹកព័ត៌មាន



# ការពារទារកដែលទើបកើតមករបស់អ្នកពីរោគក្អកមាន់

## ការចាក់ថ្នាំបង្ការរោគក្អកមាន់ក្នុងអំឡុងពេលមានផ្ទៃពោះ អាចការពារទារកដែលទើបកើតមករបស់អ្នកចាប់ពីថ្ងៃទីមួយ។

### ព័ត៌មានសំខាន់ៗសម្រាប់ស្ត្រីដែលមានផ្ទៃពោះ

- ថ្នាំចាក់បង្ការរោគក្អកមាន់នៅ២៨សប្ដាហ៍ គឺជាវិធីល្អបំផុតដើម្បីការពារទារករបស់អ្នក រហូតដល់ការចាក់ថ្នាំបង្ការរោគលើកទីមួយរបស់ពួកគេនៅអាយុប្រាំមួយសប្ដាហ៍
- ថ្នាំចាក់បង្ការរោគឥឡូវនេះមានផ្ដល់ជូនដោយឥតគិតថ្លៃ សម្រាប់ស្ត្រីមានផ្ទៃពោះក្នុងរដ្ឋ NSW
- ទារករបស់អ្នកនឹងនៅតែត្រូវការថ្នាំចាក់បង្ការរោគក្អកមាន់ នៅអាយុប្រាំមួយសប្ដាហ៍
- រោគក្អកមាន់គឺជារោគដ៏ធ្ងន់ធ្ងរ ហើយមានសក្ដានុពលគំរាមកំហែងដល់ជីវិត។

### តើរោគក្អកមាន់ជាអ្វី ?

រោគក្អកមាន់គឺជាជំងឺបាក់តេរីឆ្លងយ៉ាងខ្លាំង ដែលបណ្ដាលឲ្យកើតមានរយៈពេលក្អកយ៉ាងធ្ងន់ធ្ងរ។ ក្នុងមនុស្សជំទង់ រោគសញ្ញាទាំងឡាយអាចស្រាល ក៏ប៉ុន្តែប្រសិនបើជំងឺបង្ករោគនេះវាឆ្លងទៅទារកដែលពុំទាន់បានចាក់ថ្នាំបង្ការរោគ វាអាចគំរាមកំហែងដល់ជីវិត។

### តើទារករបស់ខ្ញុំប្រឈមមុខនឹងគ្រោះថ្នាក់ឬ ?

ពិតណាស់។ ទារកទាំងឡាយមិនអាចចាក់ថ្នាំបង្ការរោគប្រឆាំងនឹងរោគក្អកមាន់បានទេ រហូតទាល់តែគេមានអាយុប្រាំមួយសប្ដាហ៍។ ការចាក់ថ្នាំបង្ការរោគក្អកមាន់ គឺល្អបំផុតពេលណាធ្វើឡើងក្នុង២៨សប្ដាហ៍នៅពេលមានផ្ទៃពោះម្ដងៗ ការនេះគឺដើម្បីផ្ដល់ពេលសម្រាប់ដងខ្លួនរបស់អ្នកផលិតអង្គបដិបក្ខ ដែលនឹងហុចបន្តទៅទារករបស់អ្នកមុនពេលកើតមក ។ អង្គបដិបក្ខទាំងនេះនឹងការពារទារករបស់អ្នក រហូតដល់ពួកគេត្រៀមខ្លួនជាស្រេចដើម្បីទទួលការចាក់ថ្នាំបង្ការរោគផ្ទាល់របស់ពួកគេនៅអាយុ៦សប្ដាហ៍។

### តើការចាក់ថ្នាំបង្ការរោគមានសុវត្ថិភាពឬ ?

ពិតណាស់។ ថ្នាំចាក់បង្ការរោគគឺមានសុវត្ថិភាពសម្រាប់ទាំងស្ត្រីមានផ្ទៃពោះ និងទារក ប្រសិនបើបានផ្ដល់ឲ្យក្នុងអំឡុងពេលមានផ្ទៃពោះ។ ការសិក្សាពីសហរដ្ឋអាមេរិក និងប្រទេសអង់គ្លេសទាក់ទិនច្រើនជាង 40 000 នៃស្ត្រីមានផ្ទៃពោះ ត្រូវបានគេរកឃើញមានប្រតិកម្មរាយរងស្រាលប៉ុណ្ណោះដូចជាឈឺ ឬឡើងក្រហមនៅលើដៃត្រង់កន្លែងចាក់ថ្នាំ។ វាមិនបង្កើនភាពស្មុគស្មាញក្នុងអំឡុងពេលមានផ្ទៃពោះទេ ហើយក្រុមប្រឹក្សាស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រសុខភាពជាតិក្នុងពេលថ្មីៗនេះ បានធ្វើការណែនាំទាន់បច្ចុប្បន្នភាពសម្រាប់ស្ត្រីមានផ្ទៃពោះដែលត្រូវចាក់ថ្នាំបង្ការរោគនៅត្រីមាសទីបីរបស់ពួកគេ។

### តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីខ្លះ?

និយាយទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកនៅថ្ងៃនេះ អំពីការទទួលថ្នាំចាក់បង្ការរោគក្អកមាន់ដោយឥតគិតថ្លៃនៅត្រីមាសទីបី។

ភាពស៊ាំនឹងជំងឺដែលអ្នកទទួលបានពីថ្នាំចាក់បង្ការរោគក្អកមាន់នឹងសាបរលាបនៅពេលក្រោយមក ដូច្នេះអ្នកចាំបាច់ត្រូវការចាក់ថ្នាំបង្ការរោគក្នុងអំឡុងពេលមានផ្ទៃពោះម្ដងៗនៅប្រហែល២៨សប្ដាហ៍។

នេះជាការសំខាន់ផងដែរ គឺអស់អ្នកដែលនឹងនៅជិតស្និទ្ធជាមួយទារករបស់អ្នកនៅក្នុងប៉ុន្មានសប្ដាហ៍ដំបូងនៃអាយុរបស់ទារកទទួលថ្នាំចាក់បង្ការរោគក្អកមាន់។ សូមឲ្យបានប្រាកដថាកូនៗឯទៀតរបស់អ្នក បានទទួលថ្នាំបង្ការរោគទាន់បច្ចុប្បន្នភាពរបស់ពួកគេ ហើយស្នើសុំអ្នកថែរក្សា និងសមាជិកគ្រួសារជិតស្និទ្ធទាំងឡាយដែលពុំទាន់បានចាក់ថ្នាំបង្ការរោគក្អកមាន់ក្នុងរយៈពេល១០ឆ្នាំកន្លងមក ដើម្បីឲ្យប្រាកដថាពួកគេបានទទួលការចាក់ថ្នាំបង្ការរោគយ៉ាងហោចណាស់ពីរសប្ដាហ៍ មុនដែលពួកគេមានការទាក់ទងណាមួយជាមួយទារករបស់អ្នក។

អ្នកក៏អាចការពារខ្លួនអ្នក និងទារករបស់អ្នកផងដែរពីប្រតិកម្មដ៏មានគ្រោះថ្នាក់នៃជំងឺគ្រុនផ្ដាសាយ ក្នុងអំឡុងពេលមានផ្ទៃពោះ ដោយស្នើសុំវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីទទួលថ្នាំចាក់ការពារជំងឺគ្រុនផ្ដាសាយ ដែលអាចផ្ដល់ឲ្យក្នុងដំណាក់កាលណាមួយក្នុងអំឡុងពេលមានផ្ទៃពោះ។

*ថ្នាំចាក់បង្ការរោគក្អកមាន់ឥតគិតថ្លៃក្នុងអំឡុងពេលមានផ្ទៃពោះ គឺជាវិធីល្អបំផុតដើម្បីការពារទារកដែលទើបកើតមករបស់អ្នកចាប់ពីថ្ងៃទីមួយ។ សូមនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់អ្នកនៅថ្ងៃនេះ អំពីថ្នាំចាក់បង្ការរោគទាំងឡាយ។*

ព័ត៌មានបន្ថែមអំពីរោគក្អកមាន់ មានផ្ដល់ជូននៅត្រង់វិបសាយ
**www.health.nsw.gov.au/whoopingcough**

NSW GOVERNMENT | Health

Khmer

ចូលមើលវិបសាយ **health.nsw.gov.au/protectnewborns**